ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

ព្រះរាជក្រឹត្យ នស/រកត/១០២៣/២៣១២

# ការរៀបចំ និងការប្រព្រឹត្តិទៅ
# នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ព្រះរាជក្រឹត្យ

នស/រកត/១០២៣/៤៣១៤

ស្តីពី

**ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រសួងមុខ... រដ្ឋបាល
ចូល លេខៈ...៤.៣០១...
មកដល់ថ្ងៃទី០១ ខែ១១ ឆ្នាំ២៣
ម៉ោង ១៥:០៤

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **គ.ក.ស.** ដើម្បីដឹកនាំនិងសម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

## ជំពូកទី២
## ភារកិច្ចរបស់ គ.ក.ស.

**មាត្រា២ .-**

**គ.ក.ស.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំនិងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព
- ពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព
- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្ត គាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព
- សិក្សានិងរៀបចំក្របខណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់គុណភាពនៃសេវាសាធារណៈ និងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- លើកសំណើជូនរាជរដ្ឋាភិបាលសម្រេចលើក្របខណ្ឌគតិយុត្ត យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី សម្រាប់គាំទ្រនិងបម្រើឱ្យការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល គាំទ្រ និងជំរុញការធ្វើបរិវត្តកម្មសេវាសាធារណៈ នវានុវត្តន៍ និងការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ
- ជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃភាពជាអ្នកដឹកនាំអង្គភាពសាធារណៈ និងដំណើរការនៃអង្គភាពសាធារណៈឱ្យកាន់តែប្រសើរ
- រៀបចំនិងដាក់ឱ្យអនុវត្តឯកសារក្របខណ្ឌសមត្ថភាពជាអ្នកដឹកនាំ និងវាយតម្លៃនិងទទួលស្គាល់ភាពជាអ្នកដឹកនាំគំរូក្នុងរដ្ឋបាលសាធារណៈ
- សិក្សាប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាលជាលក្ខណៈកញ្ចប់ ដោយគ្របដណ្តប់ទាំងមន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ យោធិន មន្ត្រីនគរបាលជាតិ មន្ត្រីផ្សេងទៀត និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងលើកសំណើអំពីការកែទម្រង់ប្រព័ន្ធបៀវត្សជាលក្ខណៈកញ្ចប់
- សិក្សានិងរៀបចំការធ្វើវិចារណកម្មមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន
- គាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលនិងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យនិងសម្រេចលើសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ



- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាលនិងជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣

## សមាសភាពនិងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ក.ស.

**មាត្រា៣ ._**

**គ.ក.ស.** មានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប អនុប្រធាន
- រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ អនុប្រធានប្រចាំការ
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអធិការកិច្ច១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក

- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន១រូប សមាជិក
- ប្រធានអនុគណៈកម្មាធិការទាំង៤ នៃ **គ.ក.ស**. សមាជិក
- រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ មួយចំនួន សមាជិក
- តំណាងគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ស**. សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងនៃ **គ.ក.ស**. ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ស**. តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី។

**មាត្រា៤** .-

**គ.ក.ស**. មានអនុគណៈកម្មាធិការចំនួន៤(បួន) ដើម្បីជួយបំពេញការងាររួមមាន៖

- អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍
- អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ
- អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស
- អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រី។

អនុគណៈកម្មាធិការនីមួយៗត្រូវដឹកនាំដោយរដ្ឋលេខាធិការមួយរូប នៃក្រសួងមុខងារសាធារណៈ និងមានសមាសភាពផ្សេងទៀតមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនៃ **គ.ក.ស**. តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃអនុគណៈកម្មាធិការនីមួយៗត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ស**. តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី។

របៀបរបបនិងនីតិវិធីនៃការបំពេញការងាររបស់អនុគណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ស**.។

**មាត្រា៥** .-

អនុគណៈកម្មាធិការបរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធនឹងការលើកកម្ពស់បរិវត្តកម្មសេវាសាធារណៈ និងនវានុវត្តន៍ រួមទាំងការធ្វើឌីជីថលូបនីយកម្មសេវា
- ដឹកនាំសម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា យុទ្ធសាស្ត្រ ផែនការសកម្មភាពនិងកម្មវិធីពាក់ព័ន្ធនឹងការលើកកម្ពស់បរិវត្តកម្មសេវាសាធារណៈនិងនវានុវត្តន៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- សិក្សាស្រាវជ្រាវអំពីទស្សនាទាននិងការវិវត្តថ្មីៗនៃការផ្តល់សេវាសាធារណៈ ជាពិសេសការវិវត្តនៃឌីជីថលូបនីយកម្មសេវា
- វិភាគលើឯកសារនិងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងពិនិត្យអំពីលទ្ធភាពធ្វើបរិវត្តកម្មសេវាសាធារណៈមួយចំនួនទៅកម្រិតឌីជីថល
- សិក្សានិងរៀបចំដំណើរការការងារក្នុងការបង្កើតមជ្ឈមណ្ឌលសេវាក្រោមដំបូលតែមួយ
- ប្រមូលនិងចងក្រងទិន្នន័យដែលពាក់ព័ន្ធនឹងលទ្ធផលនៃការអនុវត្តស្តង់ដាសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- វិភាគ វាយតម្លៃ ផ្តល់អនុសាសន៍ និងតាមដានការអនុវត្តស្តង់ដាសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- កសាងលិខិតបទដ្ឋានគតិយុត្តនិងជំរុញការអនុវត្តមូលនិធិនវានុវត្តន៍ ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំនិងនវានុវត្តន៍នៅក្នុងការផ្តល់សេវាសាធារណៈនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ស.**។

**មាត្រា៦ .-**

អនុគណៈកម្មាធិការឧត្តមភាពសេវាសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការជំរុញឧត្តមភាពសេវាសាធារណៈ
- កសាងកម្មវិធីនិងផែនការសកម្មភាពសម្រាប់កែលម្អនិងជំរុញឧត្តមភាពសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំយន្តការនានា ដើម្បីគាំទ្រដល់ដំណើរការនៃការកែលម្អនិងការវាយតម្លៃសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល ជំរុញ និងផ្តល់យោបល់ក្នុងការកែលម្អគុណភាពសេវាសាធារណៈដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាននិងត្រួតពិនិត្យការកែលម្អគុណភាពសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃនិងការទទួលស្គាល់ក្រសួង ស្ថាប័ន និងអង្គភាពផ្តល់សេវាសាធារណៈដែលមានស្នាដៃ
- រៀបចំប្រព័ន្ធវាយតម្លៃស្នាដៃផ្អែកលើសមិទ្ធកម្មរបស់មន្ត្រីម្នាក់ៗ ដែលបម្រើការងារក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- វាយតម្លៃនិងផ្តល់វិញ្ញាបនបត្រនិងពានរង្វាន់ជូនអង្គភាពផ្តល់សេវាសាធារណៈ នៅក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្នាដៃឆ្នើមក្នុងការកែលម្អគុណភាពសេវាសាធារណៈ
- រៀបចំនិងលើកសំណើបង្កើតយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ផ្តល់យោបល់ផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ
- សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំកម្មវិធីនិងលើកសំណើបណ្តុះបណ្តាលស្តីពីសេវាសាធារណៈ
- រៀបចំបោះពុម្ពលិខិតបទដ្ឋានគតិយុត្តនិងឯកសារពាក់ព័ន្ធនឹងសេវាសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ស.**។

**មាត្រា៧ .-**

អនុគណៈកម្មាធិការគ្រប់គ្រងធនធានមនុស្ស ស្ថាប័ន និងបៀវត្ស មានភារកិច្ចដូចខាងក្រោម៖

- សិក្សានិងជំរុញការរៀបចំក្របខណ្ឌគោលនយោបាយ ក្របខណ្ឌគតិយុត្ត និងផែនការអភិវឌ្ឍស្ថាប័ន
- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការជ្រើសរើសនិងការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- រៀបចំនិងជំរុញការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ព្រមទាំងធ្វើការវាយតម្លៃនិងជំរុញការកែលម្អគុណភាពធនធានមនុស្ស
- រៀបចំកសាងកម្រងនីតិវិធី លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្សដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំផែនការមេស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- សិក្សាលទ្ធភាពនិងជំរុញការអនុវត្តការពង្រាយមន្ត្រីរាជការឱ្យស្របតាមតម្រូវការការងារ
- សិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយអំពីបទពិសោធ និងការអនុវត្តល្អនៃការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន
- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នក្នុងវិស័យសាធារណៈ
- ផ្តួចផ្តើមរៀបចំលើកសំណើ ដើម្បីដាក់ចេញគោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អនុវត្តប្រព័ន្ធលាភការនិងសមិទ្ធកម្ម
- សិក្សានិងវិភាគរចនាសម្ព័ន្ធ ទំហំការងារ ចំនួនមន្ត្រីរាជការ និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នក្នុងវិស័យសាធារណៈនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កសាងឯកសារមូលដ្ឋានសម្រាប់ការវិភាគមុខងារ ការពិពណ៌នាមុខតំណែងមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដឹកនាំការពិភាក្សានិងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ពីគោលការណ៍និងវិធីសាស្ត្រ សម្រាប់ការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យនិងផ្តល់យោបល់លើការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀត សម្រាប់កំណែទម្រង់ពាក់ព័ន្ធនឹងការចំណាយបន្ទុកបុគ្គលិកក្នុងវិស័យសាធារណៈ

- រៀបចំនិងកសាងឯកសារមូលដ្ឋានសម្រាប់ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- រៀបចំនិងដាក់ឱ្យអនុវត្តក្រមសីលធម៌របស់មន្ត្រីរាជការសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ស**.។

**មាត្រា៨ .-**

អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រី មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ការកសាងសមត្ថភាពធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- កសាងយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីសម្រាប់ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការសាធារណៈក្នុងរយៈពេលមធ្យមនិងរយៈពេលវែង
- សហការជាមួយស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលតាមបណ្តាក្រសួង ស្ថាប័ននានា ដើម្បីរៀបចំផែនការ កម្មវិធី វគ្គសិក្សាជាប្រព័ន្ធរួមមួយដែលអាចឆ្លើយតបនឹងសំណូមពរ តម្រូវការក្នុងការលើកកម្ពស់សមត្ថភាពជំនាញ និងសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- សិក្សានិងវិភាគពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញដែលត្រូវការតាមក្រសួង ស្ថាប័ន ដើម្បីរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តសម្រាប់ដាក់ឱ្យអនុវត្ត
- សហការជាមួយស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលតាមបណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជនរួមទាំងដៃគូអភិវឌ្ឍ ដើម្បីស្វែងរកអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង តាមមុខជំនាញជូនមន្ត្រីរាជការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រវត្តិសមត្ថភាពការងារ សម្រាប់រៀបចំផែនការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការស៊ីវិលក្នុងមុខងារសាធារណៈ
- រៀបចំចងក្រងនិងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មាននៃការបណ្តុះបណ្តាល និងរៀបចំយន្តការសម្រាប់ការវាយតម្លៃប្រសិទ្ធភាពនៃការបណ្តុះបណ្តាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ស**.។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ក.ស.

**មាត្រា៩ .-**

**គ.ក.ស**. ត្រូវរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាសនិងកិច្ចប្រជុំផ្សេងទៀត តាមការសម្រេចរបស់ប្រធាន។ កិច្ចប្រជុំនីមួយៗ ត្រូវដឹកនាំដោយប្រធានឬអនុប្រធានប្រចាំការ តាមការប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ ប្រធាន **គ.ក.ស**. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន អង្គភាព ឬអាជ្ញាធររួមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមប្រជុំនិងបំពេញការងារ។

**គ.ក.ស**. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំក្នុងឋានៈជាសមាជិកសង្កេតការណ៍ ឬជាអ្នកផ្តល់យោបល់តាមការចាំបាច់។

**មាត្រា១០.-**

**គ.ក.ស**. ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំដើម្បីត្រួតពិនិត្យអំពីវឌ្ឍនភាពការងារនិងលើកទិសដៅការងារបន្ត ព្រមទាំងធ្វើរបាយការណ៍ប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា១១.-**

សមាជិក **គ.ក.ស**. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីមានធុរៈចាំបាច់ពុំអាចចូលរួមកិច្ចប្រជុំបាន ប្រធានស្ថាប័នត្រូវចាត់តាំងតំណាងមកចូលរួមប្រជុំជំនួស ដោយធ្វើប្រតិភូកម្មអំណាចឱ្យតំណាងរូបនោះមានសិទ្ធិសម្រេចបាន។

**មាត្រា១២.-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈដើម្បីគាំទ្រនិងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ។

សមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ស**.។

**មាត្រា១៣.-**

**គ.ក.ស**. ត្រូវចាត់ចែងឱ្យមានការត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយយន្តការវាយតម្លៃផ្ទៃក្នុងរបស់ខ្លួនឬអាចស្នើឱ្យមានការពិនិត្យនិងវាយតម្លៃ ដោយយន្តការខាងក្រៅដែលជាស្ថាប័នឯករាជ្យតាមការសម្រេចរបស់ប្រធាន **គ.ក.ស**.។

**មាត្រា១៤.-**

**គ.ក.ស**. មានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិ ដើម្បីជួយគាំទ្រដល់កិច្ចដំណើរការរបស់ **គ.ក.ស**. និងអនុគណៈកម្មាធិការនានានៃ **គ.ក.ស**.។

អគ្គលេខាធិការដ្ឋាន **គ.ក.ស**. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបនិងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា១៥.-**

មន្ត្រីបម្រើការងារក្នុង **គ.ក.ស**. ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្របតាមលក្ខខណ្ឌការងារតម្រូវនីមួយៗ។ ក្នុងករណីចាំបាច់ **គ.ក.ស**. អាចជ្រើសរើសអ្នកជំនាញការជាតិឬអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីរាជការនៃមុខងារសាធារណៈផ្សេងទៀត ដោយផ្អែកលើគោលការណ៍សមត្ថភាព តម្លាភាព និងការប្រកួតប្រជែងបើកទូលាយ។

**មាត្រា១៦.-**

**គ.ក.ស**. ត្រូវរៀបចំប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលចូលរួមនៅក្នុងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា១៧.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ក.ស**. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៨.-**

**គ.ក.ស**. មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងមុខងារសាធារណៈ ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## ប្រភពធនធាននិងថវិការបស់ គ.ក.ស.

**មាត្រា១៩.-**

**គ.ក.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាជាតិដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងមុខងារសាធារណៈ។

**គ.ក.ស.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងធនធានគាំទ្រផ្នែកសម្ភារៈនិងបច្ចេកទេសពីក្រសួង ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍនានា ព្រមទាំងប្រភពស្របច្បាប់ផ្សេងៗ សម្រាប់ដំណើរការការងារ។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត មានប្រភពធនធានសម្រាប់ដំណើរការការងារ ស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តសាមី។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុរបស់ **គ.ក.ស.** ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២០.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១.-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ពុធ ១១កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០២៣

នស.រកត.១០២៣.[illegible]

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្ស វិស្សុត**